**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

# លោកតំណាងពិសេសសំដែងនូវការសោកស្តាយយ៉ាងជ្រាលជ្រៅ ចំពោះការតំកល់ការផ្តន្ទាទោសដល់ បិន សំណាង និង សុខ សំអឿន

## ១២ មេសា ២០០៧

លោកតំណាងពិសេស នៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជា **លោក យ៉ាសហ៍ ហ្គាយ** សូមសំដែងនូវការសោកស្តាយយ៉ាងជ្រាលជ្រៅ ចំពោះសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ កាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៧ ពីការតំកល់ការផ្តន្ទាទោសដល់ បិន សំណាង និងសុខ សំអឿន ។ តុលាការក្រុងភ្នំពេញបានផ្តន្ទាទោស បិន សំណាង និងសុខ សំអឿន អោយជាប់ពន្ធនាគារចំនួន ២០ឆ្នាំ កាល ពីថ្ងៃទី១ ខែសីហា ឆ្នាំ២០០៥ ចំពោះឃាតកម្មលើមេដឹកនាំ សហជីព លោកជា វិជ្ជា កាលពីថ្ងៃទី២២ ខែ មករា ឆ្នាំ២០០៤ ។ អយ្យការមិនបានបង្ហាញភស្តុតាងដែលគួរអោយជឿជាក់ក្នុងការភ្ជាប់បុរសទាំងពីរនាក់ នេះទៅនឹងមរណៈភាពរបស់លោកជា វិជ្ជា ទេ ។ សវនាការត្រូវបានប្រព្រឹត្តទៅដោយការរំលោភបំពានបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ រួមទាំងភាពអនាគតិរបស់តុលាការ និងគោលការណ៍សន្មត់ជាមុនថាគ្មានទោស ។

ថ្វីបើមានចំលើយពីសាក្សីថ្មីៗជាច្រើន និងមានភស្តុតាងដោះបន្ទុកយ៉ាងរឹងមាំផ្សេងទៀតយ៉ាងណាក៏ដោយ រួមទាំងការខកខានមិនបានអនុវត្តតាមការធានាជាអប្បបរិមា អោយមានសវនាការត្រឹមត្រូវតាំងពីដើមរហូតដល់ចប់នីតិវិធី ការតំកល់ទុកការផ្តន្ទាទោសដល់ បិន សំណាង និងសុខ សំអឿន គឺជាអំពើ អយុត្តិធម៌មួយដ៏ធ្ងន់ធ្ងរ ហើយសអោយឃើញពីការព្រួយបារម្ភដែលកំពុងមានរួចទៅហើយ អំពីឯក រាជ្យភាពតុលាការ នីតិរដ្ឋ និងនិទណ្ឌភាពដែលនៅតែបន្តមាននៅកម្ពុជា ។

លោកតំណាងពិសេសសូមគូសបញ្ជាក់ជាថ្មីម្តងទៀតពីការអំពាវនាវរបស់លោកកាលពីលើកមុនអោយមានការស៊ើបអង្កេតទាំងស្រុងមួយ មិនលំអៀង និងដែលគួរអោយជឿទុកចិត្តបាន ក្នុងករណីឃាតកម្មលើលោកជា វិជ្ជា និងការនាំខ្លួនអ្នកទទួលខុសត្រូវចំពោះឃាតកម្មនេះមកផ្តន្ទាទោស ។

#10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cambodia@ohchr.org